# គំរូនៃសេចក្ដីសុចរិត

ប្រធានថូម៉ាស អេស ម៉នសុន

*វាគឺជាកាតព្វកិច្ចរបស់យើង ដើម្បីរស់នៅក្នុងជីវិតរបស់យើងតាមផ្លូវមួយ ដែលយើងអាចធ្វើជាគំរូនៃសេចក្ដីសុចរិត ។*

នៅរាត្រីនេះ ខ្ញុំដឹងថា អ្នករាល់គ្នា ដែលជាបងប្អូនប្រុសរបស់ខ្ញុំ ទាំងនៅក្នុងមជ្ឈមណ្ឌលសន្និសីទនេះ និងនៅទីកន្លែងផ្សេងៗទៀតរាប់ពាន់នាក់ ជាតំណាងឱ្យការប្រមូលផ្ដុំនៃបព្វជិតភាពដ៏ធំ ដែលពុំធ្លាប់មានពីមុនមក ។ យើងគឺជាផ្នែកមួយនៃភាពជាបងប្អូនប្រុសដ៏អស្ចារ្យបំផុតនៅទូទាំងពិភពលោក ។ យើងមានភ័ណ្ឌសំណាង ហើយមានពរខ្លាំងណាស់ ដើម្បីធ្វើជាពួកអ្នកកាន់បព្វជិតភាពនៃព្រះ ។

យើងត្រូវបានណែនាំ និងលើកដំកើង នៅពេលដែលយើងបានស្ដាប់សារលិខិតទាំងឡាយដែលត្រូវបានបំផុសគំនិត ។ ខ្ញុំសូមអធិស្ឋានដើម្បីឱ្យខ្ញុំអាចត្រូវបានគាំទ្រដោយសេចក្ដីជំនឿ និងការអធិស្ឋានរបស់អ្នករាល់គ្នា នៅពេលដែលខ្ញុំចែកចាយជាមួយអ្នករាល់គ្នានូវគំនិត និងអារម្មណ៍ទាំងនោះដែលមានក្នុងដួងចិត្តរបស់ខ្ញុំថ្មីៗនេះ ពេលដែលខ្ញុំបានរៀបចំដើម្បីថ្លែងសុន្ទរកថាទៅកាន់អ្នករាល់គ្នា ។

ក្នុងនាមជាអ្នកកាន់បព្វជិតភាព យើងបានត្រូវដាក់ឱ្យនៅលើផែនដីនេះ នៅក្នុងសម័យកាលដែលច្របូកច្របល់ ។ យើងរស់នៅក្នុងពិភពលោកដ៏ស្មុគស្មាញមួយ ដែលពោរពេញទៅដោយវិបត្តិគ្រប់ទិសទី ។ គំរោងការណ៍ខាងនយោបាយបានត្រូវបផ្លិចបំផ្លាញនូវស្ថេរភាពនៃប្រជាជាតិ ពួកអ្នកដែលកាន់អំណាចផ្ដាច់ការ ឱបក្រសោបអំណាច ហើយផ្នែកជាច្រើននៃសង្គមហាក់ដូចជាត្រូវបានគេជិះជាន់ជារៀងរហូត បានដកយកនូវឱកាស ហើយបន្សល់ទុកជាមួយនឹងអារម្មណ៍នៃការបរាជ័យ ។

យើងដែលជាអ្នកដែលត្រូវបានតែងតាំងនូវបព្វជិតភាពនៃព្រះ អាចធ្វើឱ្យមានភាពខុសប្លែកគ្នាបាន ។ នៅពេលដែលយើងមានគុណសម្បត្តិគ្រប់គ្រាន់សំរាប់ជំនួយនៃព្រះអម្ចាស់ យើងអាចសាងឡើងនូវតិរិយាបទនៃក្មេងប្រុស យើងអាចជួយពួកបុរស យើងអាចសំរេចនូវអព្ភូតហេតុនៅក្នុងការបំរើដ៏បរិសុទ្ធរបស់ទ្រង់ ។ ឱកាសរបស់យើងគ្មានការកំណត់ឡើយ ។

វាគឺជាការទទួលខុសត្រូវរបស់យើងដើម្បីធ្វើជាគំរូ ។ យើងត្រូវបានពង្រឹងដោយសេចក្ដីពិតថា កម្លាំងដ៏អស្ចារ្យជាងគេបំផុតនៅក្នុងពិភពលោកសព្វថ្ងៃនេះ គឺជាអំណាចនៃព្រះនៅពេលដែលអំណាចនេះជះឥទ្ធិពលតាមរយៈមនុស្ស ។ ប្រសិនបើយើងធ្វើការងាររបស់ព្រះអម្ចាស់ បងប្អូនប្រុសទាំងអស់គ្នា នោះយើងនឹងមានសិទ្ធិទទួលជំនួយរបស់ព្រះអម្ចាស់ ។ សូមកុំភ្លេចនូវសេចក្ដីពិតនោះ ។ ប្រាកដណាស់ជំនួយដ៏ទេវភាពនោះ គឺអាស្រ័យទៅលើភាពសក្ដិសមរបស់យើង ។ បុរសម្នាក់ត្រូវតែសួរខ្លួនឯងថា : តើដៃរបស់ខ្ញុំជ្រះស្អាតដែរឬទេ? តើចិត្តរបស់ខ្ញុំបរិសុទ្ធដែរឬទេ? តើខ្ញុំជាអ្នកបំរើនៃព្រះអម្ចាស់ ដែលមានភាពសក្ដិសមដែរឬទេ?

យើងត្រូវបានរុំព័ទ្ធទៅដោយវត្ថុជាច្រើន ដែលត្រូវបានរៀបចំឡើងដើម្បីបង្វែរចំណាប់អារម្មណ៍របស់យើងចេញពីវត្ថុទាំងនោះ ដែលមានគុណធម៌ និងសុចរិត ហើយអូសទាញយើងទៅនឹងអ្វីដែលអាចបណ្ដាលឱ្យយើងពុំមាន

ភាពសក្តិសម ដើម្បីអនុវត្តបព្វជិតភាពដែលយើងកាន់ ។ ខ្ញុំពុំមែនគ្រាន់តែនិយាយទៅកាន់យុវជននៃបព្វជិតភាពអើរ៉ុន ប៉ុណ្ណោះទេ ប៉ុន្តែទៅកាន់មនុស្សគ្រប់វ័យទាំងអស់ផងដែរ ។ ការល្បួងកើតមានជាទម្រង់ផ្សេងៗគ្នានៅក្នុងជីវិតរបស់យើង ។

បងប្អូនប្រុស តើយើងមានភាពសក្តិសមនៅគ្រប់ពេលវេលា ដើម្បីអនុវត្តនូវកាតព្វកិច្ចពិសិដ្ឋ ដែលបានភ្ជាប់ជាមួយនឹងបព្វជិតភាពដែលយើងកាន់ដែរឬទេ? យុវជន---អ្នករាល់គ្នាដែលជាសង្ឃ---តើអ្នកជ្រះស្អាតនៅក្នុងខ្លួន និងវិញ្ញាណដែរឬទេ ពេលដែលអ្នកអង្គុយនៅឯតុសាក្រាម៉ង់នៅថ្ងៃអាទិត្យ ដើម្បីប្រសិទ្ធពរនូវនិមិត្តរូបសាក្រាម៉ង់នោះ? យុវជនដែលជាគ្រូ តើអ្នកមានភាពសក្តិសមដើម្បីរៀបចំសាក្រាម៉ង់ដែរឬទេ? ឌីកុន នៅពេលដែលអ្នកចែកសាក្រាម៉ង់ដល់សមាជិកសាសនាចក្រ តើអ្នកធ្វើកិច្ចការនោះដោយដឹងថា អ្នកមានគុណសម្បត្តិគ្រប់គ្រាន់ខាងវិញ្ញាណដើម្បីធ្វើកិច្ចការនោះដែរឬទេ? តើអ្នករាល់គ្នាយល់យ៉ាងពេញលេញនូវសារៈសំខាន់នៃ *រាល់* កាតព្វកិច្ចពិសិដ្ឋដែលអ្នកធ្វើដែរឬទេ?

មិត្តវ័យក្មេងទាំងឡាយរបស់យើងអើយ ចូររឹងប៉ឹងឡើង ។ ទស្សនវិជ្ជារបស់មនុស្សជាច្រើនមាននៅជុំវិញយើង ។ ជាញឹកញាប់ ភាពងាយស្រួលនៅសព្វថ្ងៃ គឺជាការដោះសារមួយសំរាប់ការប្រព្រឹត្តអំពើបាប ។ សូមកុំភាន់ច្រឡំឱ្យសោះថា នៅពីក្រោយស្បែកមុខនោះ គឺជាការឈឺចិត្ត អពមង្គល និងការឈឺចាប់ ។ អ្នករាល់គ្នាដឹងនូវអ្វីដែលខុស និងអ្វីដែលត្រូវ ហើយគ្មានការលាក់កំបាំងឡើយ ទោះបីជាយ៉ាងណាក៏ដោយ ការល្បួងអាចផ្លាស់ប្តូរឥរិយាបទនោះ ។ ធម្មជាតិនៃអំពើវិលងមានដូចគ្នា ។ ប្រសិនបើមិត្តរបស់អ្នករាល់គ្នាណាម្នាក់ជំរុញឱ្យអ្នករាល់គ្នាធ្វើនូវអ្វីមួយ ដែលអ្នកដឹងថាខុស នោះ *អ្នករាល់គ្នា* ត្រូវធ្វើជាមនុស្សម្នាក់ដែលគាំទ្រនូវអ្វីដែលត្រឹមត្រូវ ទោះបីជាអ្នកត្រូវធ្វើកិច្ចការ នោះតែម្នាក់ឯងក៏ដោយ ។ ចូរមានសេចក្តីក្លាហានខាងសីលធម៌ ដើម្បីធ្វើជាពន្លឺសំរាប់អ្នកដទៃឱ្យធ្វើតាម ។ គ្មានចំណងមិត្តភាពណាមួយដែលមានតម្លៃជាងគោលការណ៍ច្បាស់លាស់ ភាពស្អាតស្អំខាងសីលធម៌ផ្ទាល់របស់អ្នករាល់គ្នាឡើយ---ហើយនេះពិតជាអារម្មណ៍ដ៏រុងរឿងខ្លាំងណាស់ ដើម្បីដឹងថា អ្នករាល់គ្នាឈរនៅក្នុងកន្លែងដ៏ស្អាតស្អំ ដែលបានរៀបចំរបស់អ្នក ព្រមជាមួយនឹងជំនឿចិត្តថា អ្នករាល់គ្នាមានភាពសក្តិសមដើម្បីធ្វើកិច្ចការទាំងនោះ ។

បងប្អូនប្រុសនៃបព្វជិតភាពមិលគីស្សាដែក តើអ្នករាល់គ្នាបានព្យាយាមដោយឧស្សាហ៍ជារៀបរាល់ថ្ងៃដើម្បីរស់នៅទៅតាមរបៀបដែលអ្នកគួរតែរស់នៅដែរឬទេ? តើអ្នកមានសណ្តានចិត្តល្អ និងសេចក្តីស្រឡាញ់ចំពោះភរិយារបស់អ្នក និងកូនៗរបស់អ្នកដែរឬទេ? តើអ្នកមានភាពស្មោះត្រង់នៅក្នុងទំនាក់ទំនងរបស់អ្នកជាមួយនឹងអ្នកដទៃដែលនៅជុំវិញអ្នក---គ្រប់ពេល និងគ្រប់វេលាដែរឬទេ?

ប្រសិនបើមាននរណាម្នាក់ក្នុងចំណោមអ្នកទាំងអស់គ្នាបានប្រព្រឹត្តអំពើបាប ឬបានដើរខុសនៅក្នុងជីវិតរបស់អ្នក នោះនឹងមានអ្នកដែលអាចជួយអ្នករាល់គ្នាឱ្យស្អាតស្អំ និងមានភាពសក្តិសមម្តងទៀត ។ ប៊ីស្សព និងប្រធានសាខារបស់អ្នករាល់គ្នាខ្វល់ខ្វាយ ហើយមានឆន្ទៈដើម្បីជួយផ្តល់ឱ្យនូវការយល់ចិត្ត និងសេចក្តីមេត្តាករុណា ហើយនឹងធ្វើដោយអស់ពីសមត្ថភាពរបស់គាត់ ដើម្បីជួយអ្នកនៅក្នុងដំណើរការនៃការប្រែចិត្ត ដើម្បអ្នករាល់គ្នាអាចឈរនៅក្នុងសេចក្តីសុចរិតចំពោះព្រះអម្ចាស់ម្តងទៀត ។

អ្នករាល់គ្នាភាគច្រើនចងចាំប្រធាន អិន អែលដុន ថាណនើរ ដែលបំរើជាទីប្រឹក្សារបស់ប្រធាននៃសាសនាចក្រចំនួនបួនរូប ។ លោកបានផ្តល់នូវគំរូនៃសេចក្តីសុចរិតដ៏អស់កល្បជានិច្ចមួយ ពេញទាំងអាជីពមួយនៅក្នុងពាណិជ្ជកម្ម ខណៈដែលបំរើនៅក្នុងជួររដ្ឋាភិបាលនៅប្រទេសកាណាដា ហើយជាបន្តបន្ទាប់ទៀតនៅក្នុងជីវិតឯកជនរបស់លោក ។ លោកបានផ្តល់ឱ្យយើងនូវពាក្យទូន្មានដែលបំផុសគំនិតថា :

"គ្មានអ្វីមួយនឹងនាំមកនូវសេចក្តីរីករាយ និងជោគជ័យដ៏ធំ ជាងការរស់នៅស្របតាមការបង្រៀននៃដំណឹងល្អឡើយ...។

ចូរធ្វើជាគំរូ ធ្វើជាឥទ្ធិពលមួយសំរាប់សេចក្តីល្អ...។ យើងគ្រប់គ្នាត្រូវបានតែងតាំងពីមុនមកសំរាប់កិច្ចការខ្លះៗ ជាអ្នកបំរើដ៏ជំរើសរបស់ [ព្រះ] ជាអ្នកដែលទ្រង់ព្រះតំរិះថា ល្អដើម្បីប្រគល់នូវបព្វជិតភាព និងអំណាចដើម្បីធ្វើកិច្ចការនៅក្នុងព្រះនាមរបស់ទ្រង់។ ចូរចងចាំជានិច្ចថា មនុស្សទាំងអស់កំពុងសម្លឹងមើលអ្នករាល់គ្នាសំរាប់ការដឹកនាំ ហើយអ្នករាល់គ្នាកំពុងតែ ជះឥទ្ធិពលទៅលើជីវិតនៃបុគ្គលម្នាក់ៗ មិនថាជាមនុស្សល្អ ឬមនុស្សអាក្រក់ឡើយ ជាឥទ្ធិពលដែលនឹងមានចំពោះជំនាន់ទាំងឡាយនាពេលអនាគត។[1]

បងប្អូនប្រុសរបស់ខ្ញុំអើយ ខ្ញុំសូមនិយាយម្តងទៀតថា ក្នុងនាមជាពួកអ្នកកាន់បព្វជិតភាពនៃព្រះ វាគឺជាកាតព្វកិច្ចរបស់យើងដើម្បីរស់នៅក្នុងរបៀបមួយ ដែលយើងអាចធ្វើជាគំរូនៃសេចក្តីសុចរិតសំរាប់ឱ្យអ្នកដទៃធ្វើតាម។ ពេលដែលខ្ញុំសញ្ជឹងគិតពីរបៀបដែលយើងផ្តល់នូវគំរូបែបនេះឱ្យកាន់តែប្រសើរ នោះខ្ញុំបានគិតពីបទពិសោធន៍មួយដែលខ្ញុំបានមានកាលពីប៉ុន្មានឆ្នាំមុន នៅពេលដែលចូលរួមក្នុងសន្និសីទស្តេកមួយ។ នៅក្នុងសម័យប្រជុំទូទៅនោះ ខ្ញុំបានសង្កេតមើលក្មេងប្រុសម្នាក់ ដែលកំពុងអង្គុយជាមួយនឹងគ្រួសាររបស់គាត់នៅជួរខាងមុខនៃមជ្ឈមណ្ឌលស្តេក។ ខ្ញុំបានអង្គុយនៅលើវេទិកា។ នៅពេលដែលការប្រជុំបានចាប់ផ្តើមឡើង ខ្ញុំបានចាប់ផ្តើមកត់សំគាល់ឃើញថា ប្រសិនបើខ្ញុំអង្គុយគងទាក់ខ្លា ក្មេងប្រុសនោះនឹងធ្វើតាម។ ប្រសិនបើខ្ញុំប្តូរដាក់ជើងទៅលើជើងម្ខាងទៀត នោះគាត់នឹងធ្វើដូចគ្នា។ ខ្ញុំបានដាក់ដៃនៅលើភ្លៅរបស់ខ្ញុំ ហើយគាត់ក៏ធ្វើដូច្នោះផងដែរ។ ខ្ញុំបានយកដៃច្រត់ចង្ការ ហើយគាត់ក៏ធ្វើតាមដែរ។ អ្វីក៏ដោយដែលខ្ញុំធ្វើ គាត់នឹងធ្វើដំរាប់តាមសកម្មភាពរបស់ខ្ញុំ។ សកម្មភាពនេះបានបន្ត រហូតដល់ពេលដែលខ្ញុំត្រូវឡើងធ្វើសុន្ទរកថាទៅកាន់ពួកជំនុំ។ ខ្ញុំបានសំរេចចិត្តថានឹងសាកល្បងគាត់ម្តងទៀត។ ខ្ញុំបានសម្លឹងទៅគាត់ដោយត្រង់ៗ ប្រាកដណាស់ដោយបានទទួលនូវចំណាប់អារម្មណ៍របស់គាត់ ហើយបន្ទាប់មកខ្ញុំបានកំរើកត្រចៀករបស់ខ្ញុំ។ គាត់បានព្យាយាមធ្វើដូចគ្នានោះតែឥតប្រយោជន៍ ខ្ញុំបានឈ្នះគាត់! ព្រោះគាត់មិនអាចធ្វើឱ្យត្រចៀករបស់គាត់កំរើកបាន។ គាត់បានបែរទៅរកឪពុករបស់គាត់ដែលអង្គុយនៅជិតគាត់ ហើយបានខ្សឹបប្រាប់អ្វីមួយដល់ឪពុករបស់គាត់។ គាត់បានចង្អុលត្រចៀករបស់គាត់ បន្ទាប់មកបានចង្អុលមករកខ្ញុំ។ ពេលដែលឪពុករបស់គាត់បានមើលមកខ្ញុំ ពិតណាស់ដើម្បីមើលត្រចៀករបស់ខ្ញុំដែលកំពុងតែកំរើក ខ្ញុំបានអង្គុយចុះឱបដៃដោយទឹកមុខមាំ ដោយមិនកំរើកអ្វីឡើយ។ ឪពុករូបនោះបានសម្លឹងមើលកូនប្រុសរបស់គាត់ ដែលជាអ្នកចាញ់ដោយសង្ស័យ។ ទីបំផុតគាត់ញញឹមដាក់ខ្ញុំដោយអៀនខ្មាស់ ហើយបានញាក់ស្មារបស់គាត់។

ខ្ញុំបានគិតពីបទពិសោធន៍នោះអស់ជាច្រើនឆ្នាំ ពេលដែលខ្ញុំសញ្ជឹងគិតនូវរបៀប ជាពិសេសនៅពេលដែលយើងនៅក្មេង យើងចង់ធ្វើដំរាប់តាមគំរូនៃឪពុកម្តាយរបស់យើង អ្នកដឹកនាំរបស់យើង មិត្តរបស់យើង។ ព្យាការីព្រិកហាំយ៉ង់ បានមានប្រសាសន៍ថា: "យើងមិនគួរគប្បីអនុញ្ញាតឱ្យខ្លួនរបស់យើងធ្វើអ្វីមួយ ដែលយើងមិនចង់ឱ្យកូនចៅរបស់យើងធ្វើឡើយ។ យើងគប្បីធ្វើជាគំរូដល់ពួកគេ ដើម្បីពួកគេអាចយកដំរាប់តាមយើង"។[2]

ចំពោះអ្នករាល់គ្នាដែលជាឪពុកនៃក្មេងប្រុស ឬជាអ្នកដឹកនាំនៃក្មេងប្រុស ខ្ញុំសូមនិយាយថា សូមព្យាយាមធ្វើជាគំរូមួយដែលក្មេងប្រុសទាំងនោះត្រូវការ។ ពិតណាស់ ឪពុកគប្បីធ្វើជាគំរូដំបូងបង្អស់ ហើយក្មេងប្រុសនោះនឹងមានពរ ដោយមានឪពុកដែលមានភាពសក្តិសមគឺជាសំណាងយ៉ាងខ្លាំង។ ទោះបីជាយ៉ាងណាក៏ដោយ សូម្បីតែគំរូជា

គ្រួសារដោយមានឪពុក និងម្ដាយដ៏ឧស្សាហ៍ និងស្មោះត្រង់ អាចប្រើរាល់ជំនួយដែលមានប្រយោជន៏ ដែលពួកគេអាចទទួលពីមនុស្សល្អ ដែលថែទាំយ៉ាងពិតប្រាកដ។ ក៏មានក្មេងប្រុសដែលគ្មានឪពុក ឬឪពុកដែលមិនផ្ដល់នូវគំរូដែលត្រូវការនៅពេលនេះ។ ចំពោះក្មេងប្រុសនោះ ព្រះអម្ចាស់បានផ្ដល់នូវបណ្ដាញនៃពួកអ្នកជួយមួយក្រុមដែលមាននៅក្នុងសាសនាចក្រ---ជាពួកប៊ីស្សព ពួកអ្នកណែនាំ ពួកគ្រូបង្រៀន ពួកប្រធានកាយរិទ្ធ ពួកគ្រូបង្រៀនតាមផ្ទះ។ នៅពេលដែលកម្មវិធីរបស់ ព្រះអម្ចាស់កំពុងប្រតិបត្តិការ ហើយអនុវត្តដោយត្រឹមត្រូវ នោះគ្មានយុវជនណាម្នាក់នៅក្នុងសាសនាចក្រពុំមានឥទ្ធិពលនៃពួកបុរសល្អៗ នៅក្នុងជីវិតរបស់ខ្លួនឡើយ។

ប្រសិទ្ធិភាពរបស់ប៊ីស្សព អ្នកណែនាំ ឬគ្រូបង្រៀដែលបំផុសគំនិត គឺមិនជាប់ទាក់ទង់នឹងសញ្ញានៃអំណាចដែលអាចមើលឃើញ ឬភាពសំបូរសប្បាយនៃសម្ភារៈរបស់ពិលោកនេះឡើយ។ ពួកអ្នកដឹកនាំដែលមានឥទ្ធិពលបំផុតជាទូទៅគឺជាជនទាំងឡាយណាដែលបំផុសគំនិតដល់អ្នកដទៃយ៉ាងខ្លាំង ជាមួយនឹងពលិកម្មចំពោះសេចក្ដីពិត ជាអ្នកដែលធ្វើឱ្យការគោរពប្រណិបត្តិចំពោះកាតព្វកិច្ច មើលទៅសំខាន់ចំពោះភាពជាបុរស ជាអ្នកផ្លាស់ទម្លាប់សាមញ្ញខ្លះៗ ដើម្បីឱ្យយើងមើលឃើញទិដ្ឋភាពជាមនុស្សម្នាក់ដែលយើងប្រាថ្នាចង់ក្លាយខ្លួនជា។

មនុស្សម្នាក់ដែលយើងមិនគួរមើលរំលង---ជាការពិតណាស់ ជាគំរូដ៏ចំបងរបស់យើង---គឺជាព្រះអង្គសង្គ្រោះព្រះយេស៊ូវគ្រីស្ទរបស់យើង។ ការប្រសូតរបស់ទ្រង់ត្រូវបានទាយទុកជាមុនដោយពួកព្យាការី ពួកទេវតាថ្លែងនូវសេចក្ដីប្រកាសនៃការបំរើនៅលើផែនដីរបស់ទ្រង់។ ទ្រង់ "មានវ័យចំរើនធំឡើង មានកម្លាំងខាងវិញ្ញាណរឹតតែច្រើនឡើង ប្រកបដោយប្រាជ្ញាដ៏ពោរពេញ ហើយព្រះគុណនៃព្រះក៏សណ្ឋិតលើទ្រង់ផង"។[3] ចំពោះកាតព្វកិច្ចដែលបានរៀបចំឡើងដោយព្រះវរបិតារបស់ទ្រង់ ទ្រង់បានបែរព្រះភ័ក្ត្ររបស់ទ្រង់ បានសន្យានឹងព្រះទ័យរបស់ទ្រង់ ហើយបានផ្ដល់នូវព្រះជន្មរបស់ទ្រង់។ ហើយនេះគឺជីវិតដែលគ្មានអំពើបាប គ្មានភាពអត្មានិយម ខ្ពង់ខ្ពស់ និងទេវភាពណាស់។ ព្រះយេស៊ូវបានប្រកបការងារ។ ព្រះយេស៊ូវពោរពេញដោយសេចក្ដីស្រឡាញ់។ ព្រះយេស៊ូវពោរពេញដោយការបំរើ។ ព្រះយេស៊ូវពោរពេញដោយទីបន្ទាល់។ នេះជាគំរូដ៏ប្រសើរដែលយើងគួរតែយកតំរាប់តាម។ ចូរយើងចាប់ផ្ដើមធ្វើវានៅពេលនេះ និងនៅយប់នេះ។ រឿងពីមុនរបស់យើងត្រូវតែបំបាត់ចោល ហើយព្រះព្រមជាមួយនឹងការបរាជ័យ ការអស់សង្ឃឹម ការសង្ស័យ និងការឥតជំនឿកាលពីមុន។ ចំពោះជីវិតបែបថ្មីមួយ យើងធ្វើឱ្យកើតមានឡើងនូវ---ជីវិតនៃសេចក្ដីជំនឿ សេចក្ដីសង្ឃឹម ភាពអង់អាច និងសេចក្ដីរីករាយ។ គ្មានកិច្ចការណាធ្ងន់ធ្ងរនោះទេ គ្មានការទទួលខុសត្រូវណាលំបាកពេកនោះទេ គ្មានកាតព្វកិច្ចណាមួយដែលជាបន្ទុកនោះឡើយ។ យើងអាចធ្វើបានគ្រប់ការណ៏ទាំងអស់។

អស់ជាច្រើនឆ្នាំកន្លងទៅ ខ្ញុំបាននិយាយអំពីមនុស្សម្នាក់ ដែលបានយកគំរូតាមព្រះអង្គសង្គ្រោះ ជាមនុស្សម្នាក់ដែលឈរយ៉ាងមុតមាំ ហើយពិត រឹងមាំ និងសក្ដិសមនៅក្នុងព្យុះភ្លៀងនៃជីវិត។ គាត់បានដំកើងការហៅបព្វជិតភាពរបស់គាត់យ៉ាងក្លាហាន។ គាត់បានផ្ដល់គំរូមួយដល់យើងម្នាក់ៗ។ ឈ្មោះរបស់គាត់ គឺលោក ថូម៉ាស មីហ្គែល វីលសុន ជាកូនប្រុសរបស់វីលី និងជូលី វីលសុន នៃ ឡាហ្វៃយ៉ែត អាឡាបាម៉ា។

កាលពីពេលដែលគាត់នៅជាយុវវ័យ គាត់ និងគ្រួសាររបស់គាត់មិនទាន់ក្លាយជាសមាជិកនៃសាសនាចក្រនៅឡើយ គាត់បានឈឺជាទម្ងន់ដោយជម្ងឺមហារីក ដែលត្រូវបានព្យាបាលដោយពន្លឺកាំងរស្មី ហើយបានធូរស្រាលយ៉ាងខ្លាំង។ ជម្ងឺនេះ បានបណ្ដាលឱ្យគ្រួសាររបស់គាត់ដឹងថា ជីវិតមិនត្រឹមតែមានតម្លៃទេ ប៉ុន្តែវាក៏ខ្លីផងដែរ។ ពួកគេបានចាប់ផ្ដើមមើលទៅលើសាសនា ដើម្បីជួយពួកគេឱ្យឆ្លងកាត់ពេលដ៏ទុក្ខព្រួយនេះ។ បន្ទាប់មក ពួកគេត្រូវបាន

ណែនាំឱ្យមកសាសនាចក្រ ហើយទីបញ្ចប់ទាំងអស់គ្នាបានទទួលបុណ្យជ្រមុជទឹក លើកលែងតែឪពុក។ បន្ទាប់ពីការទទួលដំណឹងល្អ បងប្រុស វីលសុន វ័យក្មេងបានចង់មានឱកាសដើម្បីធ្វើជាអ្នកផ្សព្វផ្សាយសាសនាយ៉ាងខ្លាំង ទោះបីជាគាត់ចាស់ជាងយុវជនភាគច្រើន នៅពេលពួកគេបានចាប់ផ្ដើមការបំរើជាអ្នកផ្សព្វផ្សាយសាសនារបស់ពួកគេក៏ដោយ។ នៅក្នុងអាយុ 23 គាត់បានទទួលការហៅបំរើបេសកកម្មឱ្យបំរើនៅក្នុងបេសកកម្មទីក្រុងសលត៍ លេក រដ្ឋយូថាហ៍។

ដៃគូអ្នកផ្សព្វផ្សាយសាសនារបស់អែលឌើរវីលសុន បានពិពណ៌នាអំពីសេចក្ដីជំនឿរបស់គាត់ថា ជាជំនឿដែលគ្មានសង្ស័យ មិនងាករេ ហើយមិនចុះចាញ់។ គាត់គឺជាគំរូដល់មនុស្សទាំងអស់។ ទោះជាយ៉ាងណាក៏ដោយ បន្ទាប់ពីរយៈពេល 11 ខែនៃការបំរើជាអ្នកផ្សព្វផ្សាយសាសនា ជម្ងឺក៏បានត្រឡប់មកវិញ។ ឥឡូវនេះ ជម្ងឺមហារីកឆ្អឹងបានតំរូវឱ្យកាត់ដៃ និងស្មារបស់គាត់។ ប៉ុន្តែគាត់នៅតែតស៊ូនៅក្នុងកិច្ចការជាអ្នកផ្សព្វផ្សាយសាសនារបស់គាត់។

ភាពក្លាហានរបស់អែលឌើរវីលសុន និងបំណងប្រាថ្នាចង់នៅបន្តនៅក្នុងបេសកកម្មរបស់គាត់ បានជិតជាប់ក្នុងបេះដូងរបស់ឪពុកដែលមិនមែនជាសមាជិករបស់គាត់ ដែលគាត់បានសង្កេតមើលការបង្រៀនទាំងឡាយរបស់សាសនាចក្រ ហើយក៏បានក្លាយជាសមាជិកផងដែរ។

ខ្ញុំបានដឹងថាមានអ្នករៀនម្នាក់ ដែលអែលឌើរវីលសុន បានបង្រៀន បានទទួលបុណ្យជ្រមុជទឹក ប៉ុន្តែចង់ឱ្យអែលឌើរ វីលសុន ធ្វើពិធីបញ្ជាក់ឱ្យ ដែលគាត់គោរពយ៉ាងជ្រាលជ្រៅបំផុត។ គាត់ជាមួយនឹងអ្នកផ្សេងទៀតពីរបីនាក់ បានធ្វើដំណើរទៅកាន់មន្ទីរពេទ្យ នៅជិតគ្រែរបស់អែលឌើរ វីលសុន។ នៅទីនោះ ដោយដៃត្រូវបានដាក់នៅលើក្បាលរបស់គាត់ អែលឌើរ វីលសុន បានធ្វើពិធីបញ្ជាក់ដល់គាត់ ជាសមាជិកមួយរូបនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ។

អែលឌើរ វីលសុន បន្តការបំរើដ៏មានតម្លៃ ប៉ុន្តែប្រកបដោយការឈឺចាប់ពីមួយខែទៅមួយខែ ក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនា។ ការប្រសិទ្ធពរ និងការអធិស្ឋានជាច្រើនត្រូវបានផ្ដល់ឱ្យ។ ដោយសារតែគំរូនៃការលះបង់របស់គាត់ អ្នកផ្សព្វផ្សាយសាសនាជាបងប្អូនរបស់គាត់ បានរស់នៅកាន់តែជិតនឹងព្រះ។

ស្ថានភាពរាងកាយរបស់អែលឌើរ វីលសុន កាន់តែយ៉ាប់យ៉ឺនទៅ។ ទីបញ្ចប់បានខិតជិតចូលមកដល់ ហើយគាត់ត្រូវត្រឡប់ទៅផ្ទះវិញ។ គាត់បានសុំបំរើបន្ថែមមួយខែទៀត រួចហើយសំណើររបស់គាត់ត្រូវបានយល់ព្រម។ គាត់ដាក់ជំនឿទៅលើព្រះ ហើយគាត់ ថូម៉ាស មីហ្គែល វីលសុន បានទុកចិត្តដោយស្ងៀមស្ងាត់ថា ទ្វារនៃស្ថានសួគ៌បានបើក ហើយបានប្រទានពរដល់គាត់យ៉ាងច្រើន។ ឪពុកម្ដាយរបស់គាត់ វីលី និងជូលី វីលសុន និងបងប្រុសរបស់គាត់ ថូនីបានមកទីក្រុងសលត៍ លេក ដើម្បីជួយដល់កូនប្រុស និងប្អូនរបស់ពួកគេត្រឡប់ទៅផ្ទះនៅអាឡាបាម៉ាវិញ។ ទោះជាយ៉ាងណាក៏ដោយ មានការអធិស្ឋានសុំឱ្យមានពរជ័យត្រូវបានចាក់ស្រោចមកលើពួកគេ។ ក្រុមគ្រួសារបានអញ្ជើញខ្ញុំឱ្យទៅព្រះវិហារបរិសុទ្ធទន្លេរយ័រដាន់ជាមួយនឹងពួកគេ ជាកន្លែងដែលពិធីបរិសុទ្ធពិសិដ្ឋទាំងនោះ ដែលចងភ្ជាប់ក្រុមគ្រួសារសំរាប់ភាពដ៏នៅអស់កល្បជានិច្ច ក៏ដូចជាសំរាប់ជីវិតនេះផងដែរត្រូវបានធ្វើឡើង។

ខ្ញុំបាននិយាយលាទៅគ្រួសារ វីលសុន។ ខ្ញុំអាចមើលឃើញអែលឌើរ វីលសុន សូម្បីតែក្នុងពេលនេះ នៅពេលគាត់អរគុណខ្ញុំដែលបាននៅជាមួយគាត់ និងមនុស្សជាទីស្រឡាញ់របស់គាត់។ គាត់បាននិយាយថា "មិនថាអ្វី

កើតឡើងចំពោះយើងនៅក្នុងជីវិតនេះទេ ដរាបណាយើងមានដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ហើយរស់នៅតាម។ វាមិនថ្មីទេ ទោះជាខ្ញុំបង្រៀនដំណឹងល្អនៅទីនេះ ឬនៅឯម្ខាងវាំងនន ឱ្យតែខ្ញុំអាចបង្រៀនបាន" ។ ឱ! នេះជាភាពក្លាហាន។ ជាទំនុកចិត្ត និងក្តីស្រឡាញ់ខ្លាំងណាស់។ គ្រួសារ វីលសុន បានធ្វើដំណើរយ៉ាងឆ្ងាយទៅកាន់ផ្ទះ នៅឡាហ្វៃយ៉ែត ជាកន្លែងដែលអែលឌើរថូម៉ាស មីហ្គែល វីលសុន បានទទួលមរណភាពពីជីវិតនេះទៅកាន់ជីវិតដ៏នៅអស់កល្បជានិច្ច។ គាត់ត្រូវបានបញ្ចុះនៅទីនោះ ជាមួយនឹងស្លាកអ្នកផ្សព្វផ្សាយសាសនារបស់គាត់។

បងប្អូនប្រុសជាទីស្រឡាញ់របស់ខ្ញុំ ឥឡូវនេះនៅពេលយើងចាកចេញពីការប្រជុំបព្វជិតភាពទូទៅនេះ សូមឱ្យយើងទាំងអស់គ្នាប្តេជ្ញាចិត្តដើម្បីរៀបចំពេលវេលានៃឱកាសរបស់យើង ហើយគោរពបព្វជិតភាពដែលយើងកាន់ នៅក្នុងការបំរើដែលយើងផ្តល់ឱ្យ ជីវិតរស់នៅដែលយើងប្រទានពរឱ្យ និងព្រលឹងដែលយើងមានឯកសិទ្ធ ដើម្បីជួយសង្គ្រោះ។ អ្នកគឺជា "ពូជជ្រើសរើស ជាពួកសង្ឃហ្លួង ជាសាសន៍បរិសុទ្ធ" [4] ហើយអ្នកអាចធ្វើឱ្យមានការខុសប្លែក។ ចំពោះសេចក្តីពិតទាំងនេះ ដែលខ្ញុំថ្លែងទីបន្ទាល់ គឺនៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ព្រះអង្គសង្គ្រោះរបស់យើង អាម៉ែន។

កំណត់ចំណាំ

1. “For They Loved the Praise of Men More Than the Praise of God.” *Ensign,* ខែ វិច្ឆិកា ឆ្នាំ 1975, 74។

2. *Deseret News,* ថ្ងៃទី 21 ខែ មិថុនា ឆ្នាំ 1871, 235។

3. លូកា 2:40។

4. ពេត្រុស 1 2:9។